**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
ក្រសួងមហាផ្ទៃ
លេខ : ៤៩៥៩ ប្រក

# ប្រកាស

## ស្តីពី

## ការបង្កើតការិយាល័យកិច្ចការច្រកចេញចូលតែមួយ ចំណុះអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ មកជា អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ
- បានឃើញប្រកាសលេខ ០៩៥ ប្រក ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ១៩៩៤ របស់ក្រសួងមហាផ្ទៃ ស្តីពីភារកិច្ច និង រចនាសម្ព័ន្ធរបស់ទីស្តីការក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់ក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ ១** : ត្រូវបានបង្កើត**ការិយាល័យកិច្ចការច្រកចេញចូលតែមួយ** ចំណុះអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ។

**ប្រការ ២** : **ការិយាល័យកិច្ចការច្រកចេញចូលតែមួយ** មានតួនាទី ភារកិច្ចដូចខាងក្រោម :

- សិក្សាអំពីគោលការណ៍នានាសម្រាប់ការលើកកម្ពស់គុណភាព នៃការផ្តល់សេវាសាធារណៈរបស់អង្គភាពនានាចំណុះអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យបានកាន់តែល្អប្រសើរ

- គ្រប់គ្រង សម្របសម្រួល និងគាំទ្រដល់ការងារការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ នៅតាមសាលាក្រុង ស្រុក ខណ្ឌ ឱ្យមាននិរន្តរភាព និងចិរភាព
- សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា ក្នុងការសិក្សាពង្រីកជាដំណាក់កាលៗ ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅតាមក្រុង ស្រុក ខណ្ឌ ដែលមានសក្តានុពល
- សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដើម្បីរៀបចំប្រព័ន្ធ និងនីតិវិធីការងាររបស់ការិយាល័យច្រកចេញចូលតែមួយ ដោយធានាឱ្យមានសង្គតិភាពជាមួយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យ និងសិក្សាអំពីប្រតិភូកម្មមុខងារក្នុងការផ្តល់សេវាសាធារណៈ តាមរយៈការិយាល័យច្រកចេញចូលតែមួយ
- រៀបចំផែនការ សកម្មភាព និងថវិកា ព្រមទាំងការកៀរគរធនធាន ដើម្បីគាំទ្រដល់ដំណើរការការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ
- តាមដាន និងវាយតម្លៃទៅលើដំណើរការ និងលទ្ធផលការងាររបស់ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ នៅតាមសាលាក្រុង ស្រុក ខណ្ឌ
- បំពេញការងារផ្សេងទៀតតាមការចាំបាច់ និងតាមការប្រគល់ភារកិច្ចពីប្រធាននាយកដ្ឋាន ។

**ប្រការ ៣** : ការិយាល័យកិច្ចការច្រកចេញចូលតែមួយ ដឹកនាំដោយប្រធានការិយាល័យ ០១រូប និងមានអនុប្រធានការិយាល័យយ៉ាងច្រើន ០៣រូប ជាជំនួយការ ។

**ប្រការ ៤** : មន្ត្រីរាជការដែលកំពុងបម្រើការងារនៅក្នុងគម្រោងច្រកចេញចូលតែមួយ រួមទាំងសំភារៈ ទ្រព្យសម្បត្តិ និងធនធានទាំងឡាយ ដែលកំពុងគាំទ្រដល់គំរោងច្រកចេញចូលតែមួយ ត្រូវបានរៀបចំ និងផ្ទេរមកនៅក្នុងការិយាល័យដែលបង្កើតថ្មីនេះ ។

**ប្រការ ៥** : អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល ប្រធានក្រុមប្រឹក្សានីតិកម្មក្រសួងមហាផ្ទៃ ប្រធានបណ្ឌិតសភានគរបាលកម្ពុជា ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ ក្រុមប្រឹក្សា គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៤ ខែ ធ្នូ ឆ្នាំ២០១២

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ស ខេង**

**កន្លែងទទួល** :
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ*
- *គ្រប់ក្រសួង ស្ថាប័ន*
- *រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ*
- *លេខាធិការដ្ឋាន គ.ជ.អ.ប*

"*ដើម្បីជូនជ្រាប*"

- *ដូចប្រការ ៥*
- *ឯកសារ - កាលប្បវត្តិ*